ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៩៥៤៩ អពដ

ថ្ងៃអង្គារ ២កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីណែនាំ
## ស្តីពី
## ការបន្តការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យសិល្បៈ

អនុលោមតាមមាត្រា ២៥ ថ្មី និងមាត្រា ២៦ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧, ប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ, សេចក្តីណែនាំលេខ ១៨៤១០ អពដ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះអាជីវកម្មក្នុងវិស័យបញ្ចាំងខ្សែភាពយន្ត និងអាជីវកម្មជួលអចលនទ្រព្យបន្ត និងដើម្បីលើកស្ទួយវិស័យសិល្បៈនិងការផលិតភាពយន្តខ្មែរ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ឆ្នាំទី៥ និងពិធីជួបជុំសិល្បករទូទាំងប្រទេសលើកទី២ កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំអំពីការបន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់រយៈពេល ០៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដល់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យសិល្បៈ និងការផលិតភាពយន្តខ្មែរ ដូចខាងក្រោម៖

១- អនុញ្ញាតឱ្យព្យួរទុកការអនុវត្តពន្ធកាត់ទុក ១៥ % លើសួយសារនៃទ្រព្យអរូបី (ការផ្តល់សិទ្ធិបញ្ចាំងខ្សែភាពយន្តផលិតក្នុងស្រុក)
២- អនុញ្ញាតឱ្យព្យួរទុកពន្ធលើប្រាក់ចំណូលចំពោះសហគ្រាសផលិតកម្មភាពយន្តខ្មែរ។

ដើម្បីទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារនេះ សហគ្រាសផលិតភាពយន្តខ្មែរ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ
- កត់ត្រា និងកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ
- ដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ
- បំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀត។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា សហគ្រាសផលិតភាពយន្តខ្មែរទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh